57
/5

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៥
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២

សាលដីកា
លេខ: ២០៨
ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៣៦ក្រII ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់តុលាការកំពូល។

<u>*ពីបទ:*</u> *រួមភេទជាមួយអនីតិជនអាយុក្រោយ១៥ឆ្នាំ* ប្រព្រឹត្តនៅផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។

-ជនជាប់ចោទឈ្មោះ [redacted] *វីរៈ ហៅ វិន* "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ មុខរបរជាងរោងពុម្ព កើតនៅភូមិកោះឃ្លោក ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត មានទីលំនៅមុនពេលឃាត់ខ្លួនផ្ទះជួល សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោះ[redacted] "រ" នៅលើរ ទោសពីមុនគ្មាន។

ចាប់ខ្លួនថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៩, ឃុំខ្លួនថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia



Scanned by CamScanner

57/4

-មានមេធាវីលោក[redacted]សុជាតិ និងលោក [redacted] ធារី

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារុនី "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ មុខរបរស់អាងការ ទីលំនៅសព្វថ្ងៃភូមិពោធិ៍ខ្វិត ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ។

-ជនរងគ្រោះឈ្មោះ [redacted] ម័ន្ធយ៉ា ភេទស្រី អាយុ១៤ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិឡូរី ឃុំរកាក្នុង ស្រុកដូនកែវ ខេត្តតាកែវ ទីលំនៅសព្វថ្ងៃភូមិពោធិ៍ខ្វិត ឃុំព្រះបាទជាន់ជុំ ស្រុកគីរីវង់ ខេត្តតាកែវ ឪពុកឈ្មោះ[redacted]សួម "រ" ម្តាយឈ្មោះ [redacted] ចារុនី។

-មានមេធាវីលោក [redacted]សម្បត្តិ និងលោក[redacted]សុជាតា

-កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោងប្រហែល៦ល្ងាច ជនរងគ្រោះឈ្មោះ សួម ម័ន្ធយ៉ា ភេទស្រី អាយុ១៤ឆ្នាំ បានទូរស័ព្ទហៅឈ្មោះ [redacted]វីរៈ ហៅ វិន ភេទប្រុស អាយុ២០ឆ្នាំឱ្យមកយកខ្លួននៅកន្លែងចេនឡា ពេលនោះឈ្មោះ[redacted] វីរៈ ក៏បានជិះម៉ូតូឌុបមកយកឈ្មោះ យ៉ា រួចនាំគ្នាទៅហូបបាយនៅមុខចេនឡាន បន្ទាប់មកក៏បានទៅរកជួលផ្ទះសំណាក់ដេក បន្ទាប់ពីរកផ្ទះសំណាក់ដេកហើយគឺផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) រួចក៏បានទុកឥវ៉ាន់នៅទីនោះ រួចក៏នាំគ្នាជិះម៉ូតូទៅញ៉ាំបាយ និងសាច់គោអាំងនៅស្តុបទេពផន រួចហើយក៏នាំគ្នាទៅគេងនៅផ្ទះសំណាក់វិញ នៅយប់នោះឈ្មោះ [redacted]វីរៈ ក៏បានដេកគ្រែមួយពីរនាក់ ជាមួយឈ្មោះ យ៉ា (ជនរងគ្រោះ) ហើយបានរួមរ័កជាមួយឈ្មោះ យ៉ា ពីរដង លើទី១ នៅវេលាម៉ោងប្រហែល២ លើទី២ វេលាម៉ោងប្រហែល៥ភ្លឺ មុនពេលរួមរ័កឈ្មោះ យ៉ា បានដោះសំលៀកបំពាក់ខ្លួនឯង ហើយពេលរួមរ័កនោះឈ្មោះ យ៉ា ពុំមានស្រែអ្វីទេ។ ពេលរួមរ័កនោះឈ្មោះ វីរៈ បានដាក់ប្រដាប់ភេទចូលទៅក្នុងប្រដាប់ភេទរបស់ឈ្មោះ យ៉ា ទាំងពីរលើក។ លុះដល់ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង១០ព្រឹកឈ្មោះ យ៉ា បានទូរស័ព្ទហៅឈ្មោះ វីរៈ ឱ្យជួបនៅម្តុំផ្សារថ្មី ពេលទៅដល់ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថាៈឆ្លងតាមសវនាការ តំណាងអយ្យការយល់ឃើញថា នៅតែមានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ[redacted] វីរៈ ហៅ វិន ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ តាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ។ ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់នៅដដែល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១០៥"ក្រ១" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចៈ

១-ផ្តន្ទាទោសឈ្មោះ[redacted] វីរៈ ហៅ វិន ភេទប្រុស អាយុ២០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទៈ រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ចេកមាស (ក្រោយសាលាបាក់ទូក) ខណ្ឌ៧មករា រាជធានីភ្នំពេញ



Scanned by CamScanner

កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ តាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-បង្គាប់ឱ្យឈ្មោះ [redacted] រីវ: ហៅ វិន បង់ប្រាក់សំណងជម្ងឺចិត្តចំនួន៤.០០០.០០០ រៀល (បួនលានរៀល) ឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារុនី ទាមទារលើសពីនេះត្រូវច្រានចោល។

៣-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រីវ: ហៅ វិន មេធាវីការពារជនត្រូវចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចារុនី និងជនរងគ្រោះឈ្មោះ ស្វម ឆ័ន្ទយ៉ា បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ របស់ឈ្មោះ [redacted] រីវ: ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១០៥"ក្រ១" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: ជនល្មើសពិតជាបានចាប់រំលោភប្រាកដមែន សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចមានលក្ខណៈត្រឹមត្រូវហើយ សុំតម្កល់សាលក្រមទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៣៦ក្រII ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] រីវ: ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១០៥"ក្រ១" ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១២ ចំពោះមុខមេធាវីការពារជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។ បើកផ្លូវប្តឹងតក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់លោក [redacted] សុជាតិ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] រីវ: ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៣៦ក្រII ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] រីវ:។

-បានឃើញសារណាតបចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ របស់លោក [redacted] សម្បត្តិ និងលោក [redacted] សុជាតា ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។



Scanned by CamScanner

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

-មានពិរុទ្ធភាព និងភស្ដុតាងគ្រប់គ្រាន់បញ្ជាក់ថា ឈ្មោះ [redacted] វីរៈ ពិតជាបានរួមភេទជាមួយអនីតិជនអាយុ១៤ឆ្នាំ ពិតប្រាកដមែន។

-ទទួលបណ្ដឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់លោក [redacted] សុជាតិ មេធាវីការពារឱ្យឈ្មោះ [redacted]: ទុកជាត្រឹមត្រូវតាមច្បាប់។

-សុំតម្កល់សាលដីកាលេខ៣៦ក្រII ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២។

សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្ដាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] វីរៈ នាពេលសវនាការថា៖ ខ្ញុំមិនសុខចិត្តទើបខ្ញុំប្ដឹងសាទុក្ខ ព្រោះគេដាក់គុកខ្ញុំគ្មានភស្ដុតាងជាក់ស្ដែង ដោយខ្ញុំមិនបានប្រព្រឹត្តទេ តាមពិតខ្ញុំធ្លាប់ស្គាល់ ស្រលាញ់គ្នា រវាងចិត្តនឹងចិត្ត ហើយនាងបានទាមទារឱ្យខ្ញុំជូននាងទៅផ្ទះសំណាក់ តែខ្ញុំមិនស្គាល់ផ្ទះសំណាក់ទេ ហើយខ្ញុំស្គាល់នាង [redacted]យ៉ា រយៈពេលខ្លី នាងរៀនថ្នាក់ទី៩ នាងមានកំពស់ប្រហែល១,៦ម ស្ដើងល្មម។

សំណូមពរ: លើកលែងចោទប្រកាន់។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លោកមេធាវី [redacted] សុជាតិ ការពារជនជាប់ចោទឈ្មោះ [redacted] វីរៈ នាពេលសវនាការថា៖ ការចោទប្រកាន់មកលើកូនក្ដីខ្ញុំ ពីបទៈរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ តាមមាត្រា៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នោះជាការមិនត្រឹមត្រូវទេ ព្រោះគ្មានធាតុផ្សំបទល្មើសគ្រប់គ្រាន់។

សំណូមពរ: សូមមេត្តាដោះលែងកូនក្ដីខ្ញុំឱ្យមានសេរីភាព។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់លោក [redacted] សុជាតិ មេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] វីរៈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤១៧, ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

-យល់ឃើញថា ការដែលតុលាការអង្គសេចក្ដីសម្រេចផ្ដន្ទាទោសលើជនជាប់ចោទក្នុងបទរួមភេទជាមួយអនីតិជន ដោយសំអាងលើចម្លើយសារភាពរបស់ជនជាប់ចោទ, ជនរងគ្រោះ និងសាក្សី

57/1

នៅដំណាក់កាលអង្កេតនោះ គឺពុំទាន់មានមូលដ្ឋានច្បាស់លាស់នៅឡើយទេ ព្រោះថាភស្តុតាងដាក់បន្ទុកស្តីពីអត្ថិភាពនៃធាតុចេតនារបស់ជនជាប់ចោទ មិនទាន់បានបង្ហាញនៅឡើយ។ លើសពីនេះទៀតលិខិតកោសល្យវិច័យពេទ្យ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ របស់មន្ទីរពេទ្យបង្អែករាជធានីភ្នំពេញ បញ្ជាក់ថាការរួមភេទរវាងគូភាគីនេះមិនបណ្តាលឲ្យដាច់សន្ធះព្រហ្មចារីទេ តែចម្លើយជនរងគ្រោះបានបញ្ជាក់ថាក្រោយពីការរួមភេទ ខ្លួន (ជនរងគ្រោះ) បានទៅងូតទឹកឃើញមានឈាម។ ករណីនេះជាការខ្វះសំអាងហេតុ ដែលជាមូលហេតុនៃបណ្តឹងសាទុក្ខស្របតាមមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា តុលាការបានកោះហៅភាគីត្រឹមត្រូវហើយ តែមិនបានចូលខ្លួនមាពេលសវនាការនេះទេ ដូច្នេះតាមស្មារតីមាត្រា៤៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចជំនុំជម្រះបាន។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៣៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះ មិនមានលក្ខណៈត្រឹមត្រូវទេ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ៨៨ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ របស់ភាគីជនជាប់ចោទ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៣៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១១៥ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសាជាថ្មី។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី០៤ ខែកញ្ញា និងប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។



Scanned by CamScanner

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

៥



Scanned by CamScanner